# SIREN របាយការណ៍

បណ្ដាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ

គម្រោងអន្តរភ្នាក់ងារសហប្រជាជាតិស្ដីពីការជួញដូរមនុស្ស (UNIAP) ៖ដំណាក់កាលទី៣

បាងកក, ប្រទេសថៃ

ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៨ GMS-05

# ហេតុអ្វីបានជាជនរងគ្រោះដោយអំពើជួញដូរ បដិសេធជំនួយ[១]

## ព័ត៌មានត្រឡប់ទទួលបានពីជនរងគ្រោះដោយអំពើជួញដូរនៅទ្វីបអឺរ៉ុប

| | |
|---|---|
| ពាក្យគន្លឹះ | ▪ **ទីតាំង** ៖ ទ្វីបអឺរ៉ុប (ប្រទេសអាល់បានី មុលដូវ៉ា ស៊ើប៊ី)<br>▪ **ប្រធានបទ** ៖ ការជួញដូរស្ត្រី និងកុមារ, ការការពារជនរងគ្រោះ, ផលវិបាក<br>▪ **ប្រភេទនៃការវិភាគ** ៖ បទសម្ភាសន៍ជាមួយជនរងគ្រោះ |
| គោលបំណង | *ដើម្បីវិភាគស្ថានភាពជនរងគ្រោះដោយអំពើជួញដូរ និងទស្សនៈរបស់ពួកគេចំពោះសេវាការពារដែលត្រូវបានផ្ដល់ឱ្យ និងមិនត្រូវបានផ្ដល់ឱ្យពួកគេ ក្នុងគោលបំណងកំណត់ការរីកចម្រើនដែលអាចកើតមានចំពោះកិច្ចការពារជនរងគ្រោះ* |
| អ្នកនិពន្ធ | វិទ្យាស្ថានហ្វាហ្វូនៅក្នុងទីក្រុង អូស្លូ ប្រទេសន័រវេ<br>Anette Brunovskis<br>Anette.Brunovskis@fafo.no<br><br>វិទ្យាស្ថាននិចស៊ឹសនៅក្នុងទីក្រុងវៀនណា ប្រទេសអូទ្រីស<br>Rebecca Surtees<br>Rsurtees@nexusinstitute.net<br><br>Fafo NEXUS Institute |

[១] របាយការណ៍ SIRENនេះសង្ខេបពី ៖ Brunovski, A. &R. Surtees (2007) Leaving the past behind? When victims of trafficking decline assistance. Fafo AIS (Oslo) and NEXUS Institute (Vienna). របាយការណ៍នេះអាចរកបាននៅគេហទំព័រ ៖ http://www.fafo.no/pub/rapp/20040/20040.pdf.

## ករណីសិក្សា

នាង "ក"បានធ្វើចំណាកស្រុកពីស្រុកជនបទរបស់នាងដែលនៅជាប់ព្រំដែនទៅកាន់ប្រទេសនៅជិតខាងនោះដោយមានក្តីសង្ឃឹមថានឹងរកបានការងារធ្វើ និងជីវភាពរស់នៅល្អជាងមុន។ នាងបានជួបនឹងស្ត្រីម្នាក់សន្យាថាជួយនាងក្នុងការរកទីកន្លែងស្នាក់នៅសមរម្យនិងការងារធ្វើផងដែរ។ នាងមិនចេះភាសាក្នុងប្រទេសនោះទេតែទោះជាយ៉ាងនេះក្តីនាងក៏យល់ព្រមទៅជាមួយស្ត្រីម្នាក់នោះហើយទីនាងក៏ត្រូវបានគេលក់ឱ្យក្លាយជាកម្មករដែលរងការកេងប្រវ័ញ្ចកំលាំងពលកម្មជាទីបំផុត។

នគរបាលនៅទីបញ្ចប់បានធ្វើការបង្ក្រាបហើយបានរំដោះនារីមួយចំនួនចេញពីទី នោះដែលរួមទាំងនាង "ក" ផងដែរ ហើយបញ្ជូននាងទៅឱ្យស្ត្រីម្នាក់ទៀត។ ស្ត្រីរូបនេះបានប្រាប់នាងថាគាត់ នឹងជួយនាងរកកន្លែងស្នាក់នៅសមរម្យ និងការងារល្អផងដែរ ប្រសិនបើនាងទៅជាមួយគាត់។ នាង "ក" មិនស្គាល់ស្ត្រីរូបនោះច្បាស់លាស់ណាស់ណាទេពីព្រោះនាងមិនយល់ពីភាសាដែលគេប្រើក្នុងប្រទេសនោះ។ ទោះបីជាស្ត្រីរូបនោះគឺជាបុគ្គលិកអង្គការដែលជួយផ្តល់ជម្រកនៅក្នុងប្រទេសនោះ ក៏នាង"ក"នៅតែគិតថាគាត់គឺជាអ្នកជួញដូរមនុស្សម្នាក់ទៀត។

តើយើងអាចធ្វើឱ្យការការពារជនរងគ្រោះ និងមធ្យោបាយដែលត្រូវផ្តល់ឱ្យពួកគេឱ្យកាន់តែប្រសើរយ៉ាងដូចម្តេច ដើម្បីឱ្យពួកគេមិនប្រដូចកិច្ចការនោះទៅនឹងដំនើរការនៃការជួញដូរមនុស្ស? តើយើងអាចកាត់បន្ថយការឈឺចាប់ ផ្លូវអារម្មណ៍ ការភ័យខ្លាច និងការមិនទុកចិត្តឱ្យបានកំរិតអប្បរមាបានយ៉ាងដូចម្តេច? អ្វីដែលកាន់តែសំខាន់បំផុតនោះ តើយើងអាចធ្វើឱ្យកាន់តែប្រសើរឡើងនូវអ្វីដែលយើង កំពុងផ្តល់ឱ្យជនរងគ្រោះ និងវិធីដែលយើងផ្តល់ ដើម្បីឱ្យកិច្ចការនោះបានជ្រាបទៅដល់ពួកគេហើយអាចរកឃើញតម្រូវការពិតប្រាកដរបស់ពួកគេនៅក្នុងរបៀបមួយដោយបុគ្គល? ការសិក្សាមួយត្រូវបានធ្វើឡើងនៅក្នុងទ្វីបអឺរ៉ុបដើម្បីស្វែងរកចម្លើយចំពោះសំណួរសំខាន់ៗទាំងនេះ។

**ហេតុអ្វីបានជាជនរងគ្រោះដោយអំពើជួញដូរបដិសេធការផ្តល់ជំនួយ ហើយតើស្ថិតនៅក្នុងស្ថានភាពដូចម្តេច? មានមេរៀន និងវិធីសាស្ត្រមួយចំនួនជាបទពិសោធន៍ និងប្រើប្រាស់នៅក្នុងទ្វីបអឺរ៉ុប**

នៅពេលដែលជនរងគ្រោះដោយអំពើជួញដូរភាគច្រើនមិនដែលទទួលបានជំនួយ ជនរងគ្រោះមួយចំនួនដែលត្រូវបានគេផ្តល់ជំនួយ បែរជាមិនព្រមទទួលជំនួយដែលផ្តល់ឱ្យទៅវិញ។ តើដោយសារមូលហេតុអ្វី? ចំនុចចាប់ផ្តើមសំរាប់ការសិក្សានេះគឺ ប្រសិនបើស្ត្រី និងក្មេងស្រីបដិសេធជំនួយ គឺដោយសារ

ពួកគេមិនត្រូវការជំនួយទាំងនោះយើងទុកឱ្យគាត់ធ្វើតាមការសម្រេចចិត្តដោយខ្លួនឯង។ ប៉ុន្តែបើគេបដិសេធដោយសារមូលហេតុផ្សេង តែអាចទទួលផលប្រយោជន៍ពីជំនួយក្នុងទម្រង់ណាមួយនោះ បញ្ហានេះចាំបាច់ត្រូវតែដោះស្រាយជាបន្ទាន់។ ការសិក្សារបស់យើងដែលបានធ្វើឡើងនៅប្រទេសចំនួនបីក្នុងទ្វីបអឺរ៉ុបប៉ែកអាគ្នេយ៍ កំឡុងខែមេសា ដល់វិច្ឆិកា ឆ្នាំ២០០៦ មានគោលបំណងរួមចំណែកដល់កិច្ចពិភាក្សាមួយទៅលើការការពារជនរងគ្រោះត្រូវរៀបចំយ៉ាងដូចម្តេច និងតើសកម្មភាពអ្វីដែលចាំបាច់ត្រូវតែធ្វើឡើងដើម្បីបំពេញតម្រូវការ របស់ប្រជាជនដែលមានភាពចំរុះផ្សេងៗគ្នា ដែលឋិតនៅក្នុងប្រភេទនៃជនរងគ្រោះដោយអំពើជួញដូរ។

តើហេតុអ្វីបានជាមានការចែកចាយលទ្ធផលនៃការសិក្សានៅក្នុងទ្វីបអាស៊ី ដោយមានផ្ដលនូវភាពខុសគ្នាផ្នែកវប្បធម៌ និងភូមិសាស្ត្រនយោបាយរវាងតំបន់ទាំងពីរនេះ? មានមូលហេតុសំខាន់បីយ៉ាងគឺ :

១. វិធីសាស្ត្រ និងកិច្ចការវិភាគបានផ្តល់នូវរកឃើញមួយចំនួនដែលមានសារៈប្រយោជន៍ក្នុងការបង្កើននូវការការពារជនរងគ្រោះ ដោយមិនត្រឹមតែនៅទ្វីបអឺរ៉ុបនោះទេ តែអាចយកទៅប្រើប្រាស់នៅតំបន់ផ្សេងៗទៀត ឱ្យកាន់តែទូលំទូលាយជាងមុន។
២. ការស្រាវជ្រាវគូសបញ្ជាក់នូវសារៈសំខាន់នៃការយល់ដឹងស្តីអំពីតម្រូវការ និងការសម្រេចចិត្តនានារបស់ជនដែលត្រូវគេជួញដូរ ជាមួយនិងការទទួលយកវិធីសាស្ត្រ និងការវិភាគដែល មានស្រដៀងគ្នាដែលអាចមានភាពចាំបាច់សំរាប់កិច្ចប្រឹងប្រែងក្នុងកិច្ចការពារជនរងគ្រោះជាសកល។ ការធ្វើឱ្យវិធីសាស្ត្រនានាមានបទដ្ឋានត្រឹមត្រូវអាចបង្កើតឱ្យមានការវិភាគប្រៀបធៀប ជាអន្តរប្រទេស។
៣. នៅពេលដែលតម្រូវការ គោលបំណង និងស្ថានភាពរបស់ជនរងគ្រោះដោយអំពើជួញដូរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទំនងជាមានភាពខុសប្លែកពីជនរងគ្រោះនៅទ្វីបអឺរ៉ុប ភាពភ័យខ្លាច កង្វះខាតការយល់ដឹង កាតព្វកិច្ចចំពោះគ្រួសារ និងការចង់បានជីវិតរស់នៅដែលប្រសើរ គឺជាលក្ខណៈជារួមមួយ ហើយវាមានសារសំខាន់ក្នុងការយល់ដឹងពីរបៀបដែលកត្តាអស់ទាំងនេះជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់ជនរងគ្រោះដោយអំពើជួញដូរ។

តំបន់ដែលចុះទៅធ្វើការស្រាវជ្រាវ និងទំហំគំរូសម្រាប់ការសម្ភាសន៍ :

- **តំបន់ដែលចុះទៅធ្វើការស្រាវជ្រាវ :** ប្រទេសអាល់បានី និងប្រទេសមុលដូវ៉ា (ជាប្រទេសដែលផ្តលផ្តល់ជាប្រភព) ប្រទេសសើប៊ី (ជាប្រទេសសំចត/គោលដៅ/ប្រភព)--ការធ្វើបទសម្ភាសន៍នៅក្នុងទីក្រុងនៃប្រទេសទាំងនេះ និងទីប្រជុំជន ព្រមទាំងភូមិមួយចំនួនដែលគេបានជ្រើសរើស។ អ្នកស្រាវជ្រាវធ្វើដំណើរទៅកាន់ប្រទេសនិមួយៗចំនួនពីរដងនៅក្នុងមួយសប្តាហ៍ ហើយទស្សនៈកិច្ចលើកទីពីរពាក់ព័ន្ធទៅនឹងការធ្វើបទសម្ភាសន៍ឡើងវិញ ជាមួយអ្នកផ្តល់ចម្លើយលើកតំបូង និងទៅជួបជាមួយអ្នកផ្តល់សម្ភាសន៍ និងតំបន់ថ្មីៗផ្សេងទៀត។
- **ទំហំគំរូនៃការធ្វើបទសម្ភាសន៍ :** ស្ត្រីដែលត្រូវបានជួញដូរ និងស្ត្រីដែលប្រឈមមុខនឹងការជួញដូរចំនួន៥២នាក់ មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន៩០នាក់ដែល ធ្វើការនៅក្នុងកម្មវិធីផ្តល់ជំនួយផ្សេងៗ។

| | |
|---|---|
| **ចំនួនជនរងគ្រោះដោយអំពើជួញដូរដែលបានផ្តល់បទសម្ភាសន៍** | **៣៩នាក់** |
| **ចំនួនអ្នកផ្តល់បទសម្ភាសន៍ដែលជាអ្នកប្រកបអាជីវកម្មផ្លូវភេទនៅតាមផ្លូវ ដែលមានឋានៈជាជនរងគ្រោះដោយអំពើជួញដូរមិនត្រូវបានកំនត់អោយបានច្បាស់លាស់នោះទេ** | **១៣នាក់** |
| *ចំនួនជនរងគ្រោះដោយអំពើជួញដូរ និងស្ត្រីរកស៊ីផ្លូវភេទដែលផ្តល់បទសម្ភាសន៍ចំនួនពីរដង* | *៧នាក់* |
| *ចំនួនអ្នកដែលបានទទួលយកជំនួយនៅក្នុងពេលដែលធ្វើបទសម្ភាសន៍* | *៣០នាក់* |
| *ចំនួនអ្នកដែលមិនដែលត្រូវបានគេកំណត់អត្តសញ្ញាណថាជាជនដែលត្រូវបានគេជួញដូរ* | *៧នាក់* |
| *ចំនួនអ្នកដែលត្រូវបានគេកំណត់អត្តសញ្ញាណថាជាជនដែលត្រូវបានគេជួញដូរ ប៉ុន្តែបដិសេធរាល់ការផ្តល់ជាជំនួយទាំងអស់* | *២នាក់* |
| **ចំនួនអ្នកដែលធ្វើការងារសង្គម អ្នកចិត្តវិទ្យា មន្ត្រីសុខាភិបាល មេធាវី និងនគរបាលបានផ្តល់បទសម្ភាសន៍** | **៩០នាក់** |
| *ចំនួនអ្នកដែលធ្វើការងារសង្គម នគរបាល និងបុគ្គលដទៃទៀតដែលធ្វើការនៅកម្មវិធីផ្តល់ជំនួយផ្សេងៗដែលផ្តល់បទសម្ភាសន៍ចំនួនពីរដង* | *១១នាក់* |

## វិធីសាស្ត្រ

**ជំហានទី១: បទសម្ភាសន៍ជាមួយជនសំខាន់ៗដែលផ្តល់ព័ត៌មាននៅក្នុងស្ថាប័នដែលផ្តល់ជំនួយ** និងតួអង្គផ្សេងទៀតដែលពាក់ព័ន្ធនឹងផ្នែកប្រឆាំងជួញដូរមនុស្សដែលមានស្ថាប័នចំនួន ៣៥នៅក្នុងប្រទេសទាំង៣នេះ ដោយមានបទពិសោធន៍ផ្សេងៗគ្នានៅក្នុងការផ្តល់ជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរ។

**ជំហានទី២: ការជ្រើសរើសជនរងគ្រោះដោយអំពើជួញដូរជាអ្នកផ្តល់ចម្លើយ**តាមរយៈស្ថាប័នផ្តល់ជំនួយចំនួន១០។ អ្នកសិក្សាស្រាវជ្រាវមិនបានជ្រើសរើសអ្នកផ្តល់ចម្លើយនៅក្រៅពីបណ្តាញទាំងនេះ ឧទាហរណ៍ តាមរយៈមណ្ឌលផ្តល់សេវាសង្គម ក្រុមសហគមន៍ ឬស្ថាប័ននៅក្នុងស្រុកដទៃទៀតដែលអាចបង្ហាញបុគ្គលដែលធ្លាប់ត្រូវបានគេជួញដូរទៅដល់សហគមន៍របស់ពួកគេដែលអាចនាំឱ្យមាន ការមើលងាយ និងបង្កជាបញ្ហាផ្សេងទៀត។

**ជំហានទី៣: បទសម្ភាសន៍ជាមួយជនរងគ្រោះដោយអំពើជួញដូរប្រកបដោយក្រមសីលធម៌។** ដើម្បីធានានូវការអនុញ្ញាតពីអ្នកផ្តល់បទសម្ភាសន៍ គេបានផ្តល់ព័ត៌មានជាលាយលក្ខអក្សរស្តីពីគម្រោងស្រាវជ្រាវជាភាសាក្នុងប្រទេសនោះទៅដល់អ្នកដែលអាចនឹងផ្តល់ចម្លើយ។

ព័ត៌មានត្រូវបានគេលើកឡើងម្តងហើយម្តងទៀតដោយផ្ទាល់មាត់ ដែលជាសេចក្តីផ្តើមនៃបទសម្ភាសន៍និមួយៗ ហើយពេលវេលាក៏ត្រូវបានគេកំណត់ដាច់ដោយឡែកនៅចុងបញ្ចប់នៃបទសម្ភាសន៍សំរាប់សំណួរផ្សេងៗដែលអ្នកផ្តល់ចម្លើយអាចនឹងចោទសួរមកអ្នកធ្វើសម្ភាសន៍ និងដើម្បីពន្យល់ពីរបៀបដែលគេអាចទាក់ទងមកពួកយើងនៅពេលក្រោយទៀតបើសិនជាមានបញ្ហាផ្សេងៗលេចឡើងដោយសារតែបទសម្ភាសន៍ ឬការស្រាវជ្រាវនេះ។

## បញ្ហាក្រមសីលធម៌ និងលម្អៀងទំហំគំរូដែលកើតឡើងនៅពេលជ្រើសរើសជនរងគ្រោះដោយអំពើជួញដូរសម្រាប់ធ្វើសម្ភាសន៍

មានភាពខុសគ្នាយ៉ាងខ្លាំងរវាងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធនឹងការពេញចិត្តរបស់ពួកគេក្នុងការសួរសំណួរទៅដល់អ្នកដែលទទួលបានផលប្រយោជន៍ ថាតើអ្នកទាំងនោះចង់ចូលរួមនៅក្នុងការស្រាវជ្រាវឬទេ ក៏ដូចជាពាក់ព័ន្ធនឹងការពេញចិត្តរបស់ស្ថាប័នទាំងនោះក្នុងការនិយាយដោយចំហអំពីកិច្ចការរបស់ពួកគេ និងបទពិសោធន៍ដែលជនរងគ្រោះបដិសេធជំនួយ។ ប្រហែលជាមិនមានភាពភ្ញាក់ផ្អើលនោះទេចំពោះស្ថាប័នមួយចំនួនដែលមានតម្លាភាពតិចតួចនៅក្នុងការងាររបស់ពួកគេ មិនសូវជាចង់ចែករំលែកព័ត៌មានអំពីគម្រោងស្រាវជ្រាវជាមួយក្រុមអ្នកទទួលបានផលប្រយោជន៍ពីការស្រាវជ្រាវនោះ និងធ្វើការសម្រេចចិត្តក្នុងនាមអ្នកទទួលបានផលប្រយោជន៍ជាជាងឱ្យពួកគេជ្រើសរើសដោយខ្លួនឯង។ យើងមានផលលំបាកក្នុងការនិយាយថាតើទិន្នន័យរបស់យើងអាចនឹងមានភាពខុសគ្នាគួរឱ្យកត់សម្គាល់បានទៅដល់អ្នកផ្តល់ចម្លើយដែលត្រូវបានគេបែងចែកដោយត្រឹមត្រូវនៅក្នុងចំណោមស្ថាប័នខុសៗគ្នា និងរបៀបនៃការផ្តល់ជំនួយ។ ទោះជាយ៉ាងណា ឱកាសដែលមិនស្មើគ្នានៃការចូលទៅដល់អ្នកផ្តល់ចម្លើយដែលផ្អែកទៅលើស្ថាប័នដែលផ្តល់ជំនួយដល់ពួកគេ គួរតែត្រូវបានគិតថាជាការសិក្សាជាទូទៅលើការជួញដូរ។

បញ្ហាមួយដែលត្រូវបានលើកឡើងផងដែរនោះគឺ : តើនៅក្នុងទំហំប៉ុនណាដែលស្ថាប័នមួយគួរតែមានលទ្ធភាពគ្រប់គ្រង និងកំណត់នូវទំនាក់ទំនងរបស់អ្នកទទួលផលប្រយោជន៍ជាមួយនឹងពិភពខាងក្រៅដែលរួមបញ្ចូលទាំងការចូលរួមនៅក្នុងការស្រាវជ្រាវ?

*របកគំហើញសំខាន់ៗ : មានហេតុផលជាច្រើនចំពោះការបដិសេធជំនួយដែលត្រូវបានបែងចែកជា ៣ប្រភេទគឺ :(១)ស្ថានភាពបុគ្គល, (២)ផលលំបាកផ្សេងៗនៅក្នុងប្រព័ន្ធការពារជនរងគ្រោះ និង (៣) បរិបទសង្គម និងបទពិសោធន៍បុគ្គលដែលជាឧបសគ្គក្នុងការផ្តល់ជំនួយ*

## *ស្ថានភាពបុគ្គលដែលនាំឱ្យជនរងគ្រោះបដិសេធជំនួយ*

**ការទទួលយកជំនួយអាចស្ថិតក្នុងទម្រង់នៃការធ្វើចំណាកស្រុកបន្ថែមទៀត :** ស្ត្រីដែលត្រូវបានគេជួញដូរត្រឡប់ទៅកាន់ប្រទេសកំណើតរបស់ខ្លួនវិញនៅក្នុងស្ថានភាពផ្សេងៗ។ នៅក្នុងករណីភាគច្រើនការធ្វើចំណាកស្រុកលើកដំបូងរបស់ពួកគេ (ដែលក្រោយមកធ្លាក់ក្នុងការជួញដូរ)គឺជាវិធីដើម្បីទទួលបានប្រាក់ ឬ

ក៏នៅក្នុងករណីខ្លះគឺគេចចេញឱ្យផុតពីភាពក្រីក្រនៅក្នុងប្រទេសរបស់ខ្លួននោះ។ ជារឿយៗ មិនមានការផ្លាស់ប្តូរទាំងស្ថានភាពនៅក្នុងប្រទេសកំណើត និងទាំងគំនិតដែលចង់បានការរស់នៅប្រសើរជាងមុនដែលបុគ្គលនៅតែចង់ធ្វើចំណាកស្រុក។ បញ្ហានេះអាចជាករណីពិសេសមួយដែលបំណុលជំពាក់ដោយការជួញដូរកាន់តែធ្វើឱ្យស្ថានភាពលំបាកដែលមានស្រាប់នៅក្នុងប្រទេសកំណើតរបស់គេកាន់តែអាក្រក់ទៅៗ។ ជាងនេះជនរងគ្រោះដោយអំពើជួញដូរនឹងមិនអាចរួចផុតពីការជួញដូរបានដោយងាយនោះទេ ដោយសារតែពួកគេត្រូវបានគេកំណត់អត្តសញ្ញាណរួចទៅហើយ។ ពួកគេអាចត្រូវបានគេរំពឹងទុកថានឹងផ្តល់នូវចំណូលសម្រាប់អ្នកជួញដូរមនុស្ស ហើយជួនកាលមានជំពាក់បំណុលកាន់តែច្រើនឡើងៗ ព្រោះការចំណាយបន្ថែមទៀតទៅលើការជួញដូរម្តងទៀត ឬការធ្វើចំណាកស្រុកម្តងទៀត។ លើសពីនេះ នៅក្នុងករណីជាច្រើន ស្ត្រីដែលត្រូវបានគេជួញដូរស្ថិតនៅក្រោមការគាបសង្កត់តិចតួចផ្នែករាងកាយ តែនៅក្រោយគំនាបផ្លូវចិត្តធ្ងន់ធ្ងរ ដែលជារឿយៗនៅក្នុងទម្រង់នៃការគម្រាមកំហែងផ្សេងៗ។ ការដែលត្រូវបានបញ្ជូលត្រឡប់មកវិញ ជាទូទៅមិនបានផ្លាស់ប្តូរស្ថានភាពរបស់ស្ត្រីនោះនឹងអ្នកជួញដូរ ហើយគាត់នឹងមិនមានអារម្មណ៍ថាមានសេរីភាពជាងមុននោះទេ ក្នុងការទទួលយកជំនួយ ឬក៏ផ្លាស់ប្តូរការគិតចំពោះអ្នកជួញដូរ ទោះបីជាមើលពីខាងក្រៅ គាត់មានសេរីភាព។

**ទំនាក់ទំនងជាមួយគ្រួសារអាចនាំឱ្យមានការបដិសេធជំនួយ :** គ្រួសារដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចចិត្តចំពោះជំនួយ ដែលជួនកាលប៉ះពាល់ការសម្រេចចិត្តដោយប្រយោល ហើយជួនកាល ធ្វើការសម្រេចចិត្តឱ្យជនរងគ្រោះតែម្តង។ នៅក្នុងករណីជាច្រើនយើងបានរកឃើញថាគ្រួសារមិនបានជម្រុញចិត្តជនរងគ្រោះឱ្យទទួលយកជំនួយនោះទេ។ ការបដិសេធជំនួយគឺដើម្បីត្រឡប់ទៅជួបជុំគ្រួសារវិញដែលជាការបដិសេធដោយមិនបានឆ្លងកាត់ការណែនាំទេ ពីព្រោះការទទួលយកជំនួយអាចជាការចំណាយមួយយ៉ាងធំ។ ការចំណាយទាំងនោះអាចជាការចំណាយខាងផ្លូវអារម្មណ៍ដែលជនរងគ្រោះចង់បានដើម្បីចុះសំរុងជាមួយគ្រួសាររបស់គាត់វិញ។ ការចំណាយទាំងនោះក៏អាចជា"ការចំណាយសង្គម" ជាឧទាហរណ៍នៅពេលដែលអ្នកផ្តល់ជំនួយដល់ជនរងគ្រោះតម្រូវឱ្យអ្នកទទួលបានផលប្រយោជន៍កំណត់ការទាក់ទងជាមួយគ្រួសារដែលយ៉ាងហោចណាស់នៅក្នុងកំឡុងពេលស្នាក់អាស្រ័យនៅក្នុងជម្រកជួយសង្គ្រោះរបស់ស្ថាប័ន និងអាចជួបជាមួយគ្រួសារ បាននៅក្នុងមជ្ឈដ្ឋានដែលមានការគ្រប់គ្រងដូចជានៅប៉ុស្តិ៍នគរបាលជាដើម។ នៅមានផលវិបាកផ្នែកហិរញ្ញវត្ថុដែលការទទួលយកជំនួយមានន័យថាជនរងគ្រោះមិនអាចរកចំណូលបានទេពោលគឺនៅពេលទទួលយកជំនួយនោះ។ ការចំណាយទាំងអស់នេះធ្វើឱ្យជនរងគ្រោះដោយអំពើជួញដូរមួយចំនួនមិនអាចទទួលយកជំនួយបាន។

ជាងនេះ ជនរងគ្រោះតែងតែងចង់ត្រឡប់ទៅជួបជុំគ្រួសារភ្លាមៗ ប៉ុន្តែអាចដឹងថាទំនាក់ទំនងរបស់ពួកគេជាមួយនឹងក្រុមគ្រួសារមានការផ្លាស់ប្តូរទៅហើយ ឬក៏ពួកគេប្រឈមមុខនឹងបញ្ហានៅជាមួយគ្រួសារ ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍។ នៅក្នុងករណីបែបនេះ ស្ត្រីជាដំបូងបដិសេធជំនួយ ប៉ុន្តែក្រោយមកក៏ទទួលយកជំនួយវិញ ធ្វើឱ្យមានភាពបន្ទាន់ក្នុងការដែលពួកគេមានព័ត៌មានដើម្បីស្វែងរកសេវាផ្តល់ជំនួយនៅដំណាក់កាលក្រោយមក។ នៅក្នុងករណីជាច្រើន នៅពេលដែលជនរងគ្រោះដោយអំពើជួញដូរត្រឡប់មកវិញគ្រួសារមានគំនិតតិចតួច ឬគ្មានទាល់តែសោះពីមូលហេតុដែលគាត់បាត់ទៅ និងអ្វីដែលគាត់បានជួបប្រទះ។ ជនរងគ្រោះមានការលំបាកក្នុងការប្រាប់ក្រុមគ្រួសាររបស់គាត់នូវអ្វីដែលបានកើតឡើង ដែលបញ្ហានេះអាចបង្កឱ្យមានសម្ពាធផ្លូវចិត្ត និងការយល់ខុសផ្សេងៗ ហើយគ្រួសាររបស់គាត់នឹងមិនស្វែងយល់ថាស្ត្រីរងគ្រោះត្រូវការជំនួយនោះទេ។

**ជនរងគ្រោះមិនត្រូវការជំនួយ :** ហេតុផលមួយដែលបណ្តាជនរងគ្រោះអាចមិនទទួលយកជំនួយ គឺដោយសារពួកគេ (និង/ឬគ្រួសាររបស់ពួកគេ) បានសម្រេច ថាពួកគេមិនត្រូវការជំនួយដែលផ្តល់ឱ្យនោះទេ។ នៅក្នុងករណីខ្លះ គេមិនត្រូវការ ឬមិនចង់បានជំនួយ ហើយស្ត្រីរងគ្រោះចង់ដោះស្រាយបញ្ហាទាំងនោះដោយខ្លួនឯង និងបន្តរស់នៅដោយបំភ្លេចពីអតីតកាលមិនល្អដែលបានកើតឡើង។ នៅក្នុងករណីផ្សេងទៀត នៅពេលដែលជនរងគ្រោះត្រូវការជំនួយ គាត់អាចទទួលបាននូវជំនួយដែលបានមកពីប្រភពផ្សេងទៀត និងមិនត្រូវការសេវាជំនួយលក្ខណៈផ្លូវការដែលផ្តល់ដោយតួអង្គធ្វើការប្រឆាំងនឹងការជួញដូរមនុស្សទេ។ ជំនួយទាំងនោះអាចជាជំនួយពីគ្រួសារ បណ្តាញសង្គម សហគមន៍ ឬសេវាផ្តល់ជំនួយដែលមិនពាក់ព័ន្ធនឹងការជួញដូរ។ ធាតុពិត ជាទូទៅគេយល់ស្របថា នៅកន្លែងណាដែលមានជម្រើសផ្សេងទៀត ជនរងគ្រោះនឹងជ្រើសយកជម្រើសសេវាផ្តល់ជំនួយនោះ។ ការផ្តល់ជំនួយដែលមិនផ្តោតទៅលើការជួញដូរ ប៉ុន្តែទៅលើប្រជាពលរដ្ឋទូទៅ គឺត្រូវបានគេឱ្យតម្លៃជាពិសេស។

## *ផលលំបាកផ្សេងៗនៅក្នុងប្រព័ន្ធការពារជនរងគ្រោះដែលនាំឱ្យមានការបដិសេធជំនួយ*

**បញ្ហាព័ត៌មាន និងទំនាក់ទំនង :** ការមិនយល់ពីសេវាជំនួយទំនងជាមូលហេតុទូទៅមួយដែលពាក់ព័ន្ធនឹងបញ្ហាដែលជនរងគ្រោះបដិសេធជំនួយ។ ទោះបីជាជនរងគ្រោះដែលទទួលយកជំនួយ ឬមានជម្រើសពិតប្រាកដតិចតួចក្រៅពីទទួលយកជំនួយ ដោយសារឋានៈជាជនចំណាកស្រុកខុសច្បាប់បានរៀបរាប់នូវការយល់ច្រឡំដ៏ធំនៅពេលដំបូងដែលត្រូវបានផ្តល់ជំនួយ។ បណ្តាស្ត្រីដែលត្រូវបានគេជួញដូរ មានគំនិតខុស

ប្លែកគ្នាពីអ្វីទៅដែលហៅថាជំរកដោយបានគិតថា " ជាផ្ទះដែលពេញដោយមនុស្ស កុមារា កុមារី និងមានម៉ាស៊ីនថតនៅជុំវិញ"," បន្ទប់មានចំរឹង", "ជាការបោកបញ្ឆោត" ឬ" ជាផ្ទះដែលមានមនុស្សច្រើន"។ ជនរងគ្រោះផ្សេងទៀតយល់ដឹងមិនច្បាស់លាស់ថាពួកគេគួរទុកចិត្តអ្នកផ្តល់សេវាជំនួយ ឬនគរបាល និងព្រួយបារម្ភថាពួកគេនឹងត្រូវគេជួញដូរម្តងទៀត។ ការយល់ច្រឡំនេះ ដោយសារព័ត៌មានមិនគ្រប់គ្រាន់ ឬព័ត៌មានភាន់ច្រឡំ។ ជាទូទៅ ជំនួយត្រូវបានគេពន្យល់ដោយផ្ទាល់មាត់នៅក្នុងន័យទូលំទូលាយ និងជនរងគ្រោះតិចតួចណាស់ដែលទទួលបានព័ត៌មានជាលាយលក្ខណអក្សរ ដែលគួសបញ្ជាក់ពីជម្រើសជំនួយរបស់ពួកគេ។ ក៏មានបញ្ហាមួយផងដែរដែលពាក់ព័ន្ធទៅនឹងស្ថានភាពយល់ដឹងរបស់ពួកគេ ឧបសគ្គភាសា និងចំណេះដឹង និងបទពិសោធន៍របស់ពួកគេចំពោះជំនួយ។

**ស្ថាប័នដែលផ្តល់ជំនួយ :** បទពិសោធន៍ និងសាវតាររបស់ស្ត្រី និងកុមារដែលត្រូវបានគេជួញដូរមានភាពចម្រុះ។ អ្នកផ្តល់ចម្លើយរបស់យើងខុសគ្នាទៅតាមអាយុ ស្ថានភាពសេដ្ឋកិច្ច ប្រវត្តិនៃការអប់រំ ទំនាក់ទំនងជាមួយក្រុមគ្រួសារ បទពិសោធន៍ដោយអំពើជួញដូរ និងកត្តាផ្សេងទៀត។ ដោយសារតែភាពចម្រុះនេះ វាមិនមានការលំបាកឃើញថា*ទំហំមួយមិនត្រូវទាំងអស់នោះទេ* ដែលសំដៅទៅលើតម្រូវការជំនួយដែលជាក់ជាបញ្ហាប្រឈមចំពោះអ្នកផ្តល់សេវាជំនួយដែលធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរ។

ជនរងគ្រោះជាច្រើនបដិសេធជំនួយ ព្រោះពួកគេមិនអាច ឬមិនចង់ទទួលយកជំនួយនៅក្នុងទម្រង់ដែលគេផ្តល់ឱ្យ។ បញ្ហានេះអាចបណ្តាលមកពីតម្រូវការជាក់លាក់របស់ជនរងគ្រោះមិនត្រូវបានកម្មវិធីផ្តល់ជំនួយដោះស្រាយ។ គេដឹងតិចតួចពីលក្ខណៈ និងចំណុចសំខាន់ៗរបស់ជំនួយ ហើយដឹងច្រើនដោយសារវិធីគេរៀបចំ និងផ្តល់ជំនួយដូចជា កម្មវិធីដែលផ្តល់ជាជម្រកនៅក្នុងបណ្តាទីក្រុង និងនៅឆ្ងាយពីគ្រួសារ និងទាក់ទងនឹងការលះបង់ពេលវេលាដែលជនរងគ្រោះមិនអាចទទួលយកបាន ពីព្រោះគាត់ចាំបាច់ធ្វើការ និងផ្គត់ផ្គង់គ្រួសារ។

អ្វីដែលផ្ទុយពីការរំពឹងទុកនោះគឺស្ថានភាពជំនួយត្រូវបានផ្តល់ឱ្យជនរងគ្រោះនោះជួនកាលដូចនឹងដំណើរការនៃការជួញដូរមនុស្ស ហើយអាចបង្កឱ្យមានទុក្ខព្រួយ និងការភ័យខ្លាច។ ដោយមានការសន្យាផ្តល់ជំនួយដែលស្រដៀងនឹងការជួញដូរដែលជនរងគ្រោះត្រូវបានគេដឹកជញ្ជូន ហើយការផ្តល់ជំនួយដើម្បីទទួលបានជីវិតដែលល្អជាងមុន។ អ្នកផ្តល់ចម្លើយជាច្រើនភ័យខ្លាចថាពួកគេកំពុងត្រូវបានគេជួញដូរម្តងទៀតនៅពេលដែលគេនាំយកពួកគេទៅកាន់"ជម្រក" ឬប៉ុស្តិ៍នគរបាល។ នៅក្នុងករណីផ្សេងទៀត ជំនួយមិនបានគិតគូរឱ្យបានជិតដល់ពីភាពភ័យខ្លាចរបស់ជនរងគ្រោះចំពោះពួកអ្នកជួញដូរមនុស្សនោះទេ។ ជនរងគ្រោះតែងតែ

ភ័យខ្លាចថាការទទួលយកជំនួយនឹងដឹងដល់ពួកអ្នកជួញដូរ ដែលរួមដៃជាមួយអាជ្ញាធរ ហើយចុងក្រោយពួកអ្នកជួញដូរនឹងសងសឹកជនរងគ្រោះវិញ ឬក្រុមគ្រួសាររបស់ជនរងគ្រោះ។

**ការសហការរវាងបណ្តាអ្នកផ្តល់សេវាជំនួយ និងអ្នកទទួលបានផលប្រយោជន៍ :** នៅក្នុងស្ថានភាពខ្លះការស្រាវជ្រាវរបស់យើងបានរកឃើញថាមិនមែនជនរងគ្រោះនោះទេដែលតែងតែបដិសេធជំនួយ ប៉ុន្តែធាតុពិតអ្នកផ្តល់សេវាបដិសេធផ្តល់ជំនួយដល់ជនរងគ្រោះទៅវិញ។ នៅក្នុងករណីខ្លះជនរងគ្រោះត្រូវបានបណ្តេញចេញពីកម្មវិធីជំនួយ បន្ទាប់ពីពួកគេមិនគោរពបទបញ្ជាដោយចេតនា ដែលស្ថានភាពនេះ ក្រុមអ្នកធ្វើការងារសង្គមរ៉ាយរ៉ាប់ថាជា ការច្រានចោលមិនទទួលស្គាល់នឹងកិច្ចការផ្តល់ជំនួយ ប៉ុន្តែក៏អាចបង្ហាញពីសម្ពាធ និងការរំពឹងទុកដែលខុសគ្នារវាងអ្នកផ្តល់ជំនួយ និងអ្នកទទួលបានផលប្រយោជន៍។ ស្រ្តីមួយចំនួនបានរាយការណ៍ពីអាកប្បកិរិយាបង្កឱ្យមានបញ្ហាមួយរបស់បុគ្គលិកកម្មវិធីដែលរួមទាំងភាពលម្អៀង និងការមិនអើពើចំពោះជនរងគ្រោះដែលជា "នារីរកស៊ីផ្លូវភេទ" "ជនបរទេស" និង"អ្នកដែលគេមិនពេញចិត្ត"។ នៅក្នុងករណីខ្លះទៀត អ្នកទទួលបានផលប្រយោជន៍ចាកចេញដោយស្ម័គ្រចិត្ត ប៉ុន្តែក៏ព្រោះតែពួកគេយល់ឃើញថាល័ក្ខខ័ណ្ឌរបស់កម្មវិធីមិនអាចទ្រាំទ្របាន។ ជម្រកជាច្រើនមានបទបញ្ជា និងល័ក្ខខ័ណ្ឌយ៉ាងតឹងរ៉ឹងដូចជាប្រភេទជម្រកដែលបិទជិតពីពិភពខាងក្រៅ សេរីភាពត្រូវបានគេដាក់កំរិតក្នុងការដើរហើរការទាក់ទងតាមទូរស័ព្ទ និងទំនាក់ទំនងជាមួយមនុស្សនៅក្រៅកម្មវិធីដែលត្រូវបានដាក់កំណត់ ដែលចំណុចទាំងអស់នេះសុទ្ធតែត្រូវបានបញ្ជាក់ថាមានសារសំខាន់ចំពោះកិច្ចការពារជនរងគ្រោះទល់នឹងការគម្រាមកំហែង និងការសងសឹកផ្សេងៗ។ ទោះជាយ៉ាងណា ការរឹតបន្តឹងទាំងនេះហាក់ដូចជាមានភាពលើសលុបនៅក្នុងករណីជាច្រើន ហើយជនរងគ្រោះជាច្រើនដែលត្រូវបានគេផ្តល់ជំនួយបានលើកឡើងថាមានការលំបាកជាមួយនឹងភាពតឹងរ៉ឹងទាំងនោះ និងបណ្តាលឱ្យមានទុក្ខព្រួយ។ ជាងនេះ រឿងដែលជម្រកដទៃទៀតអាចផ្តល់ជំនួយដល់ជនរងគ្រោះដោយមិនមានបិទសិទ្ធិសេរីភាព និងមិនមានការរាយការណ៍ពីបញ្ហាសន្តិសុខផ្សេងៗបានលើកជាសំណួរពីពេលណា និងថាតើប្រភេទនៃវិធានការទាំងនេះមានសារសំខាន់និងសមរម្យ ឬទេ។ អ្នកផ្តល់សេវាជំនួយខ្លះបានពន្យល់ផងដែរថា ជួនកាលពួកគេត្រូវតែបដិសេធជនដែលទទួលបានផលប្រយោជន៍ដោយសារធនធានរបស់ពួកគេមានកំណត់ ហើយពួកគេត្រូវតែផ្តោតលើអ្នកដែលបង្ហាញពីសក្តានុពលខ្លាំងបំផុតសំរាប់ការផ្លាស់ប្តូរតែប៉ុណ្ណោះ។

## *បរិបទសង្គម និងបទពិសោធន៍បុគ្គលដែលអាចជាឧបសគ្គចំពោះជំនួយ*

**ទំនុកចិត្ត :** ទំនុកចិត្តជាអ្វីដែលជួយគាំទ្រឱ្យការឃើញរបស់យើងទទួលបានជោគជ័យព្រោះវាមានសារសំខាន់នៅក្នុងការសម្រេចចិត្តនានាអំពីថាតើគួរទទួល ឬមិនទទួលយកជំនួយ។ ទំនុកចិត្តគឺជាគ្រឹះនៃការងារដែលស្ថាប័នផ្តល់ជំនួយធ្វើនៅពេលដែលស្នើសុំឱ្យជនរងគ្រោះចូលទៅក្នុងកម្មវិធីដែលមិនស្គាល់ពីមុន ឬស្នាក់នៅក្នុងជម្រកដែលពួកគេមិនធ្លាប់នៅពីមុន។ ធាតុសំខាន់ជាក់លាក់ចំនួន២នៃទំនុកចិត្តដែលជាបញ្ហាគឺការមានមន្ទិលសង្ស័យចំពោះជំនួយ និងកង្វះខាតទំនុកចិត្តដោយសារបទពិសោធន៍ជាមួយជំនួយមុន។

ទាក់ទិននឹងមន្ទិលសង្ស័យ ជនរងគ្រោះជាច្រើន និងក្រុមគ្រួសាររបស់ពួកគេយ៉ាងហោចណាស់បានបញ្ជាក់ ពីភាពមន្ទិលសង្ស័យ ជនរងគ្រោះ និងអសន្តិសុខស្តីពីប្រភេទខុសគ្នានៃការធ្វើអន្តរាគមន៍ និងជំនួយ។ ជនរងគ្រោះខ្លះសង្ស័យចំពោះទម្រង់នៃជំនួយទាំងស្រុងដូចជាជំនួយខាងចិត្តសាស្ត្រដែលមិនត្រូវបានគេឱ្យតម្លៃ ឬបង្ហាញពីភាពអវិជ្ជមាននៅក្នុងសង្គម។ ជនរងគ្រោះដទៃទៀតសង្ស័យថាសេវាកម្ម"មិនត្រូវបានបង់ប្រាក់" ប៉ុន្តែអាចនឹងឱ្យពួកគេចំណាយនៅពេលក្រោយមក។ ទោះបីជាមានការទុកចិត្តគ្រប់គ្រាន់នៅក្នុងករណីពិសេសមួយក៏ដោយ វាគ្រាន់តែអាចត្រូវនឹងបុគ្គល ឬស្ថាប័នជាក់លាក់មួយប៉ុណ្ណោះដែលធ្វើឱ្យមានភាពស្មុគស្មាញចំពោះកិច្ចការរបស់ស្ថាប័នផ្សេងទៀត។ បទពិសោធន៍ជំនួយដែលមិនល្អកាលពីមុនទាំងក្នុងកិច្ចការជួញដូរ និងកិច្ចការផ្សេងទៀតតែងតែនាំឱ្យមានការបដិសេធជំនួយ។ វាមានសារសំខាន់ ក្នុងការពិចារណាពីទំនាក់ទំនងរវាងបទពិសោធន៍មិនល្អតែងបានកើតឡើងចំពោះក្រុមមនុស្សដែលត្រូវបានសង្គមទុកមួយឡែកដូចជាក្រុមជនជាតិភាគតិច ឬក្រុមអ្នករកស៊ីផ្លូវភេទ និងក្រុមដែលត្រូវបានសង្គមបំភ្លេចចោលរួចហើយ ដែលធ្លាក់ខ្លួនជាជនរងគ្រោះដោយអំពើជួញដូរ ដោយទំនងជាបដិសេធជំនួយ។

**ភាពអាម៉ាស និងការបណ្តេញចេញ :** ការទទួលយកជំនួយមិនថាតែជាជំនួយដែលផ្តល់ជម្រក ឬនៅក្នុងសហគមន៍របស់ស្ថាប័នដែលធ្វើការប្រឆាំងនឹងអំពើជួញដូរនោះទេ អាចកំណត់ថាស្ត្រីគឺជាជនរងគ្រោះដោយអំពើជួញដូរ ហើយបង្កឱ្យមានភាពអាម៉ាស់។ លើសពីនេះ ភាពអាម៉ាសនេះមិនត្រឹមតែជះឥទ្ធិពលដល់បុគ្គលផ្ទាល់នោះទេ ថែមទាំងអាចដល់ក្រុមគ្រួសារទាំងមូល ព្រមជាមួយនឹងសហគមន៍ផងដែរ។ ខណៈដែលមូលហេតុចំបងនៃភាពអាម៉ាស់សម្រាប់ជនរងគ្រោះគឺ ពេស្យាចារ នៅមានភាពអាម៉ាស់ផ្សេងទៀត នោះគឺការធ្វើចំណាកស្រុកដោយទទួលបរាជ័យ ជាពិសេសនៅក្នុងប្រទេសដែលមានចំណាកស្រុកទទួលបានជោគជ័យ "ច្រើន"។ អ្វីដែលគួរឱ្យកត់សម្គាល់គឺភាពអាម៉ាស់អាចកើតមានឡើងចំពោះអ្វីដែលគេ *គិត*ថាស្ត្រីនោះបានធ្វើ ជាជាងអ្វីដែលគាត់បានធ្វើពិតប្រាកដ។ នៅក្នុងមជ្ឈដ្ឋានជាច្រើនការចាកចេញពីស្រុកកំណើតនៅក្នុងកាលៈទេសៈណាមួយ បង្កឱ្យមានភាពខុសធម្មតាដែលរឹតតែនាំឱ្យមានភាពអាម៉ាស់

ថែមទៀត ព្រោះស្ត្រីដែលផ្លាស់ប្តូរទីកន្លែងក្រៅពីភូមិស្រុក ធ្វើឱ្យមានការសន្មតថាគាត់គឺជាស្ត្រីរកស៊ីផ្លូវភេទ ទោះបីជាមិនមានអ្វីមកបញ្ជាក់ក៏ដោយ។ ការទទួលបានជំនួយ និងការគាំទ្រដែលអ្នកដទៃ នៅក្នុងសហគមន៍ ក៏ចង់បាន (និងត្រូវការ) ដែរនោះ អាចបង្កឱ្យមានភាពច្រណែនឈ្នានីស និងការអាក់អន់ស្រពន់ចិត្តដែលរឹតតែនាំឱ្យមានការប៉ះពាល់ដល់ផ្លូវចិត្តកាន់តែខ្លាំងឡើង។

បញ្ហានេះសបញ្ជាក់នូវតម្រូវការសម្រាប់ការធ្វើ អន្តរាគមន៍ដែលមិនសូវមានភាពគគ្រឹកគគ្រេងពេកដូចជាការជួយដល់ក្រុមងាយរងគ្រោះក្នុងសង្គមជាជាង ជនរងគ្រោះដោយអំពើជួញដូរ (ដូចជាការផ្តល់ការអប់រំសន្តិសុខស្បៀង ឬក៏ការលើកកម្ពស់ការយល់ដឹង) ជាងយកបុគ្គលម្នាក់ ឬក្រុមគ្រួសារមួយជាគោលដៅក្នុងការផ្តល់ជំនួយនោះទេ។

**ការកំណត់អត្តសញ្ញាណ ជាមួយនឹងតួនាទីរបស់ជនរងគ្រោះ** ការទទួលយកជំនួយនៅក្នុងករណីជាច្រើនជាដំបូងមានការផ្លាស់ប្តូរទស្សនៈរបស់ជនរងគ្រោះចំពោះរូបគាត់ផ្ទាល់។ រឿងដែលគួរឱ្យចាប់អារម្មណ៍នោះគឺជួនកាលគំនិតផ្ទុយគ្នាត្រូវបានប្រើប្រាស់សម្រាប់កំណត់ពីជម្រើសដូចគ្នា ដោយស្ត្រីម្នាក់បញ្ជាក់ពីការទទួលយកជំនួយដោយបានលើកឡើងថាជាធម្មតាគាត់ដោះស្រាយដោយខ្លួនគាត់ "ខ្ញុំមិនមែនជាមនុស្សដែលគ្រាន់តែទទួលយកជំនួយនោះទេ" ខណៈដែលមានស្ត្រីម្នាក់ទៀតបញ្ជាក់ពីការទទួល យកជំនួយថា "ខ្ញុំមិនមែនជាមនុស្សដែលនិយាយថា *"ទេ"* ចំពោះអ្វីដែលគេផ្តល់ឱ្យខ្ញុំនោះទេ" ដែលមានន័យថាគាត់មិនល្ងង់បោះបង់ចោលឱកាសដើម្បីធ្វើឱ្យជីវិតរបស់គាត់ប្រសើរឡើងនោះទេ។ ជនរងគ្រោះជាច្រើនបានលើកឡើងពីការផ្លាស់ប្តូរចំពោះរបៀបដែលពួកគេមើលមកខ្លួនឯង បន្ទាប់ពីទទួលយកជំនួយឧទាហរណ៍ពួកគេមានទំនុកចិត្តជាងមុន ពួកគេដឹងថាពួកគេស័ក្តិសមនឹងអ្វីដែលប្រសើរជាងការឈឺចាប់ដែលពួកគេទទួលបាន ហើយពួកគេលែងមានអារម្មណ៍ថាមានទោស ឬអន់ជាងអ្នកដទៃទៀតហើយ។

ទោះបីជាយ៉ាងណា សំរាប់ជនរងគ្រោះដទៃទៀត រូបភាពពីខាងក្រៅមានភាពស្មុគស្មាញហើយមិនមែនសុទ្ធតែវិជ្ជមាននោះទេ។ ការទទួលយកជំនួយដែលផ្តោតទៅលើការជួញដូរ មានន័យថាទទួលយកតួនាទី និងអត្តសញ្ញាណជាជនរងគ្រោះដោយអំពើជួញដូរ។ តួនាទីនេះមានមុខងារច្រើននិងមានធាតុដែលប្រឆាំងគ្នាច្រើន។ ជនរងគ្រោះដោយអំពើជួញដូរ ជារឿយៗត្រូវទទួលរងនូវការអាម៉ាស់ដែលម្យ៉ាងវិញទៀត ពាក្យសំដីលេចឮជុំវិញបញ្ហានេះជួនកាលពាក់ព័ន្ធនឹងកិត្តិយសរបស់ជនរងគ្រោះ។ ដូចនេះហើយ វាមិនមានភាពងាយស្រួលសម្រាប់ស្ត្រីដែលត្រូវទទួលយកនោះទេ។ ជាងនេះទៅទៀតការទទួលយកជំនួយក៏ទាក់ទងនឹងការទទួលស្គាល់បញ្ហាធ្ងន់ធ្ងរដែលបានកើតឡើងផងដែរ ដែលវាអាចពិបាកក្នុងការជំនះដោយធម្មជាតិនៃប្រឆាំងនឹងបទពិសោធន៍ដែលអាម៉ាស់គឺការទប់ស្កាត់ និងការច្រានចោល។

បញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងតួនាទីរបស់ជនរងគ្រោះដោយអំពើជួញដូរគឺទាក់ទងជាមួយនឹង ពាក្យថាការជួញដូរ និងពាក្យដែលសំដៅក្នុងនាមជាជនរងគ្រោះក្នុងន័យទូទៅ និងជាអ្នកដែលទទួលយកជំនួយ។

## *សន្និដ្ឋាន*

ជនរងគ្រោះដែលបដិសេធជំនួយមានស្ថានភាពខុសៗគ្នា និងមានលក្ខណៈខុសៗគ្នាពីជនរងគ្រោះដែលទទួលយកជំនួយ។ យើងរកឃើញថាជនរងគ្រោះភាគច្រើនគ្រាន់តែទទួលយកជំនួយនៅពេលដែលពួកគេស្ថិតនៅក្នុងស្ថានភាពដែលលំបាកបំផុត និងគ្មានជម្រើសផ្សេងទៀត។ ផ្ទុយមកវិញ យើងក៏រកឃើញថាជនរងគ្រោះដែលមានជម្រើសផ្សេងទៀត ឬជម្រកសុវត្ថិភាពប្រភេទណាមួយផ្សេងទៀតបដិសេធជំនួយដែលផ្តោតទៅលើការជួញដូរ និងស្វែងរកជំនួយនោះនៅកន្លែងផ្សេងទៀត។ នេះអាចមានន័យថាលក្ខណៈមួយចំនួនដែលពាក់ព័ន្ធនឹងជនរងគ្រោះដោយការជួញដូរ ជាទូទៅអាចបង្ហាញថាជាជនរងគ្រោះដែលត្រូវបានគេជួយ ជាងជនរងគ្រោះដែលត្រូវគេជួញដូរ។ ជាឧទាហរណ៍ ការប៉ាន់ស្មានដែលថាជនរងគ្រោះភាគច្រើនមកពីទំនាក់ទំនងជាមួយគ្រួសារដែលមិនសូវល្អ នឹងត្រឡប់ទៅផ្ទះវិញជាងចូលទៅក្នុងកម្មវិធីជំនួយ ដែលជាហេតុនាំឱ្យបទពិសោធន៍របស់ពួកគេមិនត្រូវបានបង្ហាញឡើង។

ភាពខុសគ្នារវាងជនរងគ្រោះដែលត្រូវបានគេជួយ និងជនរងគ្រោះដែលមិនត្រូវបានគេជួយបានលើកឡើងជាលទ្ធផលសម្រាប់ការស្រាវជ្រាវ និងគោលនយោបាយ។ មានតម្រូវការយ៉ាងខ្លាំងសម្រាប់វង្វាយតម្លៃជាក់លាក់សម្រាប់កិច្ចប្រឹងប្រែងផ្តល់ជំនួយផ្នែកជួញដូរ ដើម្បីឱ្យឃើញថាតើកិច្ចប្រឹងប្រែងណាដែលបានផល និងមួយណាដែលមិនបានផល។ ទោះបីជាយ៉ាងណា កិច្ចប្រឹងប្រែងវាយតម្លៃមិនត្រឹមតែគិតពីឥទ្ធិពលទៅលើជនរងគ្រោះដែលត្រូវបានគេផ្តល់ជំនួយ ប៉ុន្តែក៏រួមបញ្ចូលអ្នកដែល**មិន**ត្រូវគេផ្តល់ជំនួយ ហើយដោយសារមូលហេតុអ្វី? តើអ្វីដែលបានកើតឡើងចំពោះពួកគេនៅក្នុងរយៈពេលវែង? តើមានភាពខុសគ្នាជាប្រព័ន្ធអ្វីខ្លះរវាងជនរងគ្រោះដែលត្រូវបានគេផ្តល់ជំនួយ និងជនរងគ្រោះដែលមិនត្រូវបានគេផ្តល់ជំនួយ? តើជនរងគ្រោះដែលមិនត្រូវបានគេផ្តល់ជំនួយត្រូវការជំនួយប្រភេទណាខុសពីជំនួយដែលគេផ្តល់ឱ្យដូចម្តេច? របាយការណ៍នេះបានលើកឡើងនូវអនុសាសន៍ចំពោះការធ្វើឱ្យប្រសើរឡើងដើម្បីធានាថាជនរងគ្រោះដោយអំពើជួញដូរអាចទទួលបានជំនួយដែលពួកគេត្រូវការ និងចង់បាន។

## *អនុសាសន៍មួយចំនួន*

**ផ្តល់ព័ត៌មានជាលាយលក្ខអក្សរ និងដោយផ្ទាល់មាត់នៅក្នុងភាសាដែលសមរម្យ និងបង្ហាញនូវការពឹងពាក់បានដោយគិតគូរដល់ការព្រួយបារម្ភបច្ចុប្បន្នរបស់ជនរងគ្រោះ :** ជាដំបូង ការទាក់ទងជាមួយជនរងគ្រោះជារឿយៗកើតឡើងនៅក្នុងស្ថានភាពខុសប្រក្រតី និងពាក់ព័ន្ធនឹងភាពភាន់ច្រឡំយ៉ាងធំចំពោះអ្វីដែលកំពុងកើតឡើង ព្រមទាំងអ្នកណាដែលជាអ្នកផ្តល់ជំនួយពិតប្រាកដ។ ភាពជោគជ័យក្នុងការផ្តល់ជំនួយផ្អែកទៅលើសមត្ថភាពផ្តល់ព័ត៌មាន និងកសាងទំនុកចិត្តនៅចំពេលដែលជនរងគ្រោះដែលស្ថិតក្នុងសភាពភាន់ច្រឡំ និងភាពអាម៉ាស់ ជាមួយនឹងសមត្ថភាពដែលមានកំណត់ដើម្បីដំណើរផលវិបាកនៃការទទួលយក និងបដិសេធជំនួយ។ សម្ភារៈដែលមានជាលាយលក្ខណអក្សរគួរតែត្រូវបានផ្តល់ឱ្យដែលត្រូវនឹងអាយុ ភាសា និងការអប់រំ ដែលរៀបរាប់នូវជំនួយដែលអាចផ្តល់ឱ្យបាន តួអង្គខុសៗគ្នានៅក្នុងដំណើរការ និងអំពីសិទ្ធិរបស់ជនរងគ្រោះ។ សម្ភារៈដែលមានជាលាយលក្ខណអក្សរអាចរកបាននៅពេលក្រោយ ហើយក្នុងដំណាក់កាលដែលមានស្ថេរភាពជាងមុននៃបទពិសោធន៍ក្រោយការជួញដូររបស់ជនរងគ្រោះ ទោះបីជាគាត់បានបដិសេធជំនួយកាលពីដំបូង។ ពាក់ព័ន្ធនឹងការកសាងទំនុកចិត្ត ដំណាក់កាលមួយគួរតែកំណត់អត្តសញ្ញាណ និងដោះស្រាយការព្រួយបារម្ភនាពេលបច្ចុប្បន្នរបស់ជនរងគ្រោះ ដូចជាសំណុំឯកសារផ្សេងៗ ការផ្តល់ ចំណីអាហារ ឬបញ្ហាសុខភាព ដែលបង្ហាញថាជំនួយនោះមិនត្រឹមតែមានពិតប្រាកដនោះទេ ប៉ុន្តែក៏មាន លទ្ធភាពផងដែរ។ ករណីដែលអ្នកផ្តល់ចម្លើយរបស់យើងភាគច្រើនទទួលនូវជំនួយដំបូងដែលពិតប្រាកដ និងជាក់លាក់ គឺនៅពេលដែលពួកគេសម្រេចទុកចិត្តអ្នកផ្តល់សេវាកម្ម ដែលចំណុចនេះគឺអាចជឿជាក់ជាងការប្រើប្រាស់ពាក្យសម្តីដែលបង្ហាញពីបំណងល្អ។

**ពិចារណាទៅលើបទបញ្ជា និងក្រិត្យក្រមពីទស្សនៈរបស់ជនរងគ្រោះ :**ការប្រើប្រាស់ក្រិត្យក្រមណាមួយទៅលើជនរងគ្រោះត្រូវបានណែនាំដោយភាពសមហេតុផលចំពោះការប្រើប្រាស់ក្រិត្យក្រមនោះ ដែលការគ្រប់គ្រងដ៏តឹងរ៉ឹង និងគោលការណ៍មគ្គុទេសក៏ចំពោះការប្រើប្រាស់ត្រឹមត្រូវដែលធានានូវសិទ្ធិរបសបុគ្គល និងការប្រព្រឹត្តប្រកបដោយក្រមសីលធម៌ និងធានាថាមិនមានការរំលោភសិទ្ធិជនរងគ្រោះឡើយ។ គោលការណ៍មគ្គុទេសក៏បែបនោះមិនទាន់មាននៅឡើយទេក្នុងពេលបច្ចុប្បន្ននេះ។ ជាងនេះគួរតែមានកិច្ចពិភាក្សាដែលស៊ីជម្រៅ ថាតើការធ្វើអន្តរាគមន៍បែបនោះសមរម្យចំពោះជនរងគ្រោះដោយអំពើជួញដូរដែរឬទេ និងនៅពេលណា? តើឥទ្ធិពលដែលជួយធ្វើឱ្យប្រសើរឡើងអ្វីដែលគេចង់បាន និងលទ្ធភាពរបស់ឥទ្ធិពលនោះក្នុងការសម្រេចគោលដៅ។ ប្រសិនបើក្រិត្យក្រមប្រភេទនោះត្រូវបានគេ ប្រើប្រាស់ គួរតែមាន ស្ថាប័នផ្លូវការដែលអាចទទួលយកពាក្យបណ្តឹងផ្សេងៗ ហើយក៏ជាស្ថាប័នដែល ស្ថាប័ន និងបុគ្គលនានាអាចទទួលខុសត្រូវក្នុងករណីដែលមានការរំលោភបំពាន ឬបញ្ហាកើតឡើង។

**តម្រូវការឱ្យមានការធានាបាននូវការតាមដាន គណនេយ្យភាព និងគុណភាព :** ផ្នែកការពារជនរងគ្រោះភាគច្រើនដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិដែលមិនមានការទទួលខុសត្រូវចំពោះនរណាម្នាក់ក្រៅពីម្ចាស់ជំនួយរបស់ពួកគេ ដែលអាចសម្រេចបង្កើតនូវល័ក្ខខ័ណ្ឌផ្សេងៗក្នុងការផ្តល់ជំនួយបន្ថែមទៀត។ មានប្រព័ន្ធតិចតួចណាស់សម្រាប់ចេញនូវអាជ្ញាប័ណ្ណដល់អ្នកផ្តល់សេវាកម្មនៅក្នុងកិច្ចការនេះ ដែលមានការតាមដានការងារនេះតិចតួច និងមានយន្តការផ្លូវការតិចតួចលសម្រាប់ពាក្យបណ្តឹងក្នុងករណីដែលមានការប្រព្រឹត្តមិនសមរម្យ។ ដោយរួមផ្សំជាមួយការពិតដែលជនរងគ្រោះជាច្រើនហាក់ដូចជាជឿថាជំនួយមានសារសំខាន់នោះ បញ្ហានេះបង្កើតឱ្យមានរូបភាពគួរឱ្យព្រួយបារម្ភថាតើសិទ្ធិរបស់ជនរងគ្រោះត្រូវគេគោរព និងបង្កើតនូវសក្តានុពល ក្នុងករណីជំនួយក្លាយជាទម្រង់នៃការធ្វើឱ្យក្លាយជាជនរងគ្រោះជាលើកទីពីរ ដែលបានកើតឡើងចំពោះជនរងគ្រោះមួយចំនួយ និងជាមូលហេតុនាំឱ្យជនរងគ្រោះដទៃទៀតបដិសេធជំនួយ។

**បែងចែកធនធានគ្រប់គ្រាន់ និងគិតគូរពីតម្រូវការជំនួយដែលទូលំទូលាយជាងមុន :** ការរាប់បញ្ចូលគ្រួសាររបស់ជនរងគ្រោះនៅក្នុងជំនួយអាចកាត់បន្ថយនូវការបដិសេធជំនួយ ដោយហេតុផលមួយនៃការបដិសេធ គឺបណ្តាជនរងគ្រោះដោយអំពើជួញដូរត្រូវត្រឡប់ទៅផ្ទះវិញ និងគិតគូរពីតម្រូវការរបស់គ្រួសារ។ ចំណុចនេះអាចជួយកាត់បន្ថយការមិនទុកចិត្ត និងមន្ទិលសង្ស័យរបស់គ្រួសារចំពោះជំនួយ និងអ្នកផ្តល់សេវាកម្ម។ ការអនុញ្ញាតឱ្យឪពុកម្តាយនាំយកកូនរបស់ពួកគេមកកម្មវិធីជំនួយមានសារសំខាន់ស្រដៀងគ្នាដែរ ទោះបីជាត្រូវការការគិតដោយប្រុងប្រយ័ត្នថាតើកិច្ចការនេះត្រូវធ្វើយ៉ាងដូចម្តេច។ ទោះបីជាយ៉ាងណា នៅពេលដែលអ្នកផ្តល់សេវាជាច្រើនព្យាយាមដោយមានកង្វះខាតធនធានហិរញ្ញវត្ថុ ដែលជារឿយៗតម្រូវការរបស់ជនរងគ្រោះ (ក៏ដូចជាចំនួនជនរងគ្រោះ)លើសពីធនធានដែលមាន ដែលតម្រូវឱ្យបែងចែកធនធានសមរម្យ។

**បង្កើតកម្មវិធីផ្សេងៗដែលមិនមែនកំណត់អត្តសញ្ញាណ និងមិនធ្វើឱ្យមានភាពអាម៉ាស់ :** ជំនួយទៅកាន់ជនរងគ្រោះដោយអំពើជួញដូរអាចមានភាពអាម៉ាស់តិចជាងមុន ប្រសិនបើជំនួយនោះស្ថិតនៅក្នុងសេវាកម្មសង្គម ដើម្បីឱ្យជំនួយអាចត្រូវបានទទួលនៅក្នុងស្ថានភាពភាពងាយរងគ្រោះជាជាងក្នុងនាមជាជនរងគ្រោះដោយអំពើជួញដូរ។ ការផ្តល់ឱកាសសម្រាប់ជំនួយដែលមិនពាក់ព័ន្ធនឹងការចាកចេញពីសហគមន៍ និងស្នាក់នៅក្នុងជម្រកប្រមូលផ្តុំអាចជាជម្រើសល្អសម្រាប់ជនរងគ្រោះជាច្រើនដែលមានអារម្មណ៍ថាមិនអាចចាក-ចេញពីឪពុកម្តាយ ឬកូនរបស់ពួកគេបាន ឬអ្នកដែលមិនអាចបោះបង់ចំណូលនៅពេលទទួលយកជំនួយបាន។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការងាររបស់វិទ្យាស្ថានហ្វាហ្វ៉ូនៅក្នុងប្រទេសន័រវេ៉ ឬវិទ្យាស្ថាននិចសឹសនៅក្នុងប្រទេសអូទ្រីស សូមទាក់ទងបណ្តាអ្នកស្រាវជ្រាវជាន់ខ្ពស់មួយចំនួនដូចជា Anette Brunovskis and Rebecca Surtees នៅអាស័យដ្ឋាននៅក្នុងទំព័រខាងមុខ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីគម្រោង SIREN របស់ UNIAP សូមទាក់ទងលោក Paul Buckley ដែលមានអ៊ីម៉ែល paul.buckley@undp.org.

**SIREN គឺជាគម្រោងផ្តួចផ្តើមដែលគាំទ្រដោយ :**

**United Nations Inter-Agency Project on Human Trafficking**
**Regional Project Management Office (UNIAP/PMO)**
**United Nations Building**
**7th Floor, Block B**
**Rajadamnern Nok Avenue, Bangkok 10200**
**THAILAND**

**www.no-trafficking.org**